# ព្រះរាជក្រម

នស/រកម/០១០៦/០០១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានិងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

www.pheakdeylaw.com

# ច្បាប់

# ស្តីពី

# ការទូទាត់ថវិកាទូទៅរបស់រដ្ឋ

# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

www.pheakdeylaw.com

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានយល់ព្រមតាមការអនុវត្តន៍នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ។ ការអនុវត្តន៍នេះ លេចចេញជាលទ្ធផលដូចមានចែងក្នុងតារាងសរុបខាងក្រោមនេះ :

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៣ | ការអនុវត្តន៍ថវិកាឆ្នាំ ២០០៣ |
|---|---|---|
| សរុបចំណូល = (I.១ + II.១) | ២.៨៣០.០០០ | ២.៧៤១.១៣០ |
| សរុបចំណាយ = (I. ២ +II.២) | ២.៨៣០.០០០ | ៣.០៤៤.៧៤០ |
| ចំនួននិទភាពនៃគណនេយ្យចំណូល/ចំណាយ | — | (-)៣០៣.៦១០ |
| I. កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាដែលបានអនុវត្តដោយរតនាគារជាតិ | | |
| I.១ ចំណូលថវិកា | ២.១៣០.០០០ | ១.៩០៣.៦៣៨ |
| • ចំណូលចរន្ត | ១.៩៨០.០០០ | ១.៧៥៣.២៣២ |
| • ចំណូលជាមូលធនក្នុងប្រទេស | ២៥.០០០ | ៣១.៣៧៥ |
| • ចំណូលជាមូលធនក្រៅប្រទេស | ១២៥.០០០ | ១១៩.០៣១ |
| I.២ ចំណាយថវិកា | ២.១៣០.០០០ | ២.២០៧.២៤៨ |
| • ចំណាយចរន្ត | ១.៧៦៥.០០០ | ១.៧៥៨.១៤៤ |
| • ចំណាយជាមូលធន | ៣៦៥.០០០ | ៤៤៩.១០៤ |
| II. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ដែលបានអនុវត្តក្រៅរតនាគារជាតិ[១] | | |
| II.១ ធនធានជាមូលធនសំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៧០០.០០០ | ៨៣៧.៤៩២ |
| II.២ចំណាយជាមូលធនដោយធនធានសំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៧០០.០០០ | ៨៣៧.៤៩២ |

(១) គំរោងវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ដែលបានលើកឡើងនេះ គ្រាន់តែជាការចង្អុលបង្ហាញបញ្ជាក់ ពីព្រោះកិច្ចប្រតិបត្តិការដែលបានអនុវត្តផ្ទាល់ដោយហិរញ្ញប្បទានក្រៅប្រទេស មិនឆ្លងកាត់រតនាគារជាតិនិងមិនបានចុះកិច្ចហិរញ្ញការគណនេយ្យទៅក្នុងលេខាធិការរតនាគារជាតិទេ កិច្ចប្រតិបត្តិការនេះ គឺជាលទ្ធផលដែលសំរេចបានដោយមានទំនាក់ទំនងផ្ទាល់ជាមួយអ្នកផ្តល់មូលនិធិ ។

**មាត្រា ២.-**

ចំណូលថវិកាដែលបានអនុវត្តដោយរតនាគារជាតិ ត្រូវបានលំអិតតាមមាតិកាថវិកា នៅក្នុងតារាង "ក" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

ចំណាយថវិកាដែលបានអនុវត្តដោយរតនាគារជាតិ ក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០៣ ត្រូវបានលំអិតតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែល និង តាមជំពូកនៅក្នុងតារាង "ខ" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

តារាង "ខ១" ដែលភ្ជាប់មកជាមួយច្បាប់នេះ គឺជាបញ្ជីនៃចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ដែលសំរេចបានក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០៣ និងដែលបានបែងចែកតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែល ។

លទ្ធផលដែលសំរេចបានស្តីពីវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០៣ ចំពោះចំណូលត្រូវបានលំអិតតាមមាតិកាថវិកា ដូចមាននៅក្នុងភាគទី II នៃតារាង "ក" និង ចំពោះចំណាយត្រូវបានលំអិតនៅក្នុងតារាង "ខ២" ដូចមានជូនភ្ជាប់មកជាមួយច្បាប់នេះ ។

### ជំពូកទី ២

### បទប្បញ្ញត្តិ

### ស្តីពីកិច្ចប្រតិបត្តិការចំណូលចំណាយថវិកា

### ដែលបានអនុវត្តដោយរតនាគារជាតិសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

**មាត្រា ៣.-**

ការប្រមូលចំណូល ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋពីពន្ធដារ វិភាគទានអាករផលិតផល និងផលទុន ព្រមទាំងការសំរេចបាននូវអំណោយ មូលនិធិបរិភាគ និងធនធានដែលបានមកពីការខ្ចី ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ មានចំនួនទឹកប្រាក់សរុប..................២.១៣០.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់..........១.៩០៣.៦៣៨ លានរៀល

ដូច្នេះមានចំណូលខ្វះចំនួន..................(-)២២៦.៣៦២ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តន៍ដូចតទៅ :

ចំណូលចរន្តៈ

-គំរោង................១.៩៨០.០០០ លានរៀល

-ការសំរេចបាន......១.៧៣៣.២៣២ លានរៀល

-មានចំនួនខ្វះ........(-)២៤៦.៧៦៨ លានរៀល

ចំណូលជាមូលធនក្នុងប្រទេស :

-គំរោង....................២៥.០០០ លានរៀល

-ការសំរេចបាន...........៣១.៣៧៥ លានរៀល

-មានចំនួនលើស........(+)៦.៣៧៥ លានរៀល

ចំណូលជាមូលធនក្រៅប្រទេស :

-គំរោង..................១២៥.០០០ លានរៀល

-ការសំរេចបាន..........១៣៩.០៣១ លានរៀល

-មានចំនួនលើស......(+)១៤.០៣១ លានរៀល

**មាត្រា ៤.-**

ចំណាយថវិកាទូទៅរបស់រដ្ឋ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ មានចំនួនទឹកប្រាក់សរុប.............២.១៣០.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់............២.២០៧.២៤៨ លានរៀល

ដូច្នេះមានចំណាយលើសឥណទានថវិកាចំនួន....(+)៧៧.២៤៨ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តន៍ដូចតទៅ :

ចំណាយចរន្ត

-គំរោង..............១.៧៦៥.០០០ លានរៀល

-ការសំរេចបាន.......១.៧៥៨.១៤៤ លានរៀល

-មានចំនួនខ្វះ...........(-)៦.៨៥៦ លានរៀល

ចំណាយជាមូលធននៃវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស :

-គំរោង................៣៤០.០០០ លានរៀល

-ការសំរេចបាន........៣៣៣.១៩០ លានរៀល

www.pheakdeylaw.com

-មានចំនួនខ្វះ............(-)៦.៨១០ លានរៀល

ចំណាយជាមូលធននៃការវិលសំបំណុល :

-គំរោង..................២៥.០០០ លានរៀល

-ការសំរេចបាន..........១១៥.៩១៥ លានរៀល

-មានចំនួនលើស.......(+)៩០.៩១៥ លានរៀល

**មាត្រា ៥.-**

ការអនុវត្តន៍កិច្ចប្រតិបត្តិការចំណូល និង ចំណាយតាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ដែលបានសំរេចដោយធនាគារជាតិ ដូចមានចែងនៅក្នុងមាត្រា ៣ និងមាត្រា ៤ នៃច្បាប់នេះបានបង្ហាញជាលទ្ធផលនូវនិនភាពគណនេយ្យនៃចំណូល និងចំណាយដូចតទៅ :

-ចំណូលថវិកា ដែលបានសំរេចដោយធនាគារជាតិសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ មានចំនួន................................ ១.៩០៣.៦៣៨ លានរៀល

-ចំណាយថវិកា ដែលបានសំរេចដោយធនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ មានចំនួន..................................២.២០៧.២៤៨ លានរៀល

-និនភាពគណនេយ្យពិតនៃចំណូលនិងចំណាយ..(-)៣០៣.៦១០ លានរៀល

និនភាពគណនេយ្យនេះ គឺជាលទ្ធផលនៃ :

-និនភាពនៃចំណូលចរន្ត និង ចំណាយចរន្ត....(-)២៤.៩១២ លានរៀល

-និង និនភាពនៅក្នុងកិច្ចប្រតិបត្តិការជាមូលធន...(-)២៧៨.៦៩៨ លានរៀល

ដោយអនុលោមទៅតាមបទប្បញ្ញត្តិក្នុងមាត្រា ៥៧ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ ន.ស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និនភាពគណនេយ្យនៃចំណូល និង ចំណាយសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ មានចំនួនទឹកប្រាក់ (-)៣០៣.៦១០ លានរៀល ត្រូវបានកត់ត្រានៅក្នុងគណនីលទ្ធផលដែលបានបើកនៅក្នុងលេខនានៃធនាគារជាតិ ។

www.pheakdeylaw.com

## ជំពូកទី ៣

## បទប្បញ្ញត្តិ

## ស្តីពីវិនិយោគសាធារណៈ

## ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់

## ដែលបានអនុវត្តក្រៅរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

**មាត្រា ៦.-**

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានអនុវត្តក្រៅរតនាគារជាតិ និង ដែលបានគ្រោងទុក សរុបចំណូលស្មើនឹងសរុបចំណាយ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ មានចំនួនទឹកប្រាក់...................៧០០.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់.............៨៣៧.៤៩២ លានរៀល

ដូច្នេះមានចំនួនលើស....................(+)១៣៧.៤៩២ លានរៀល

## ជំពូកទី ៤

## បទប្បញ្ញត្តិស្តីពី

## តុល្យភាពហិរញ្ញវត្ថុសាធារណៈ

## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

**មាត្រា ៧.-**

តុល្យភាពហិរញ្ញវត្ថុសាធារណៈជាស្ថានភាពនៃថវិកាទូទៅរបស់រដ្ឋ បានបង្ហាញនូវប្រភេទនៃកិច្ចប្រតិបត្តិការដូចតទៅ :

-កិច្ចប្រតិបត្តិការថវិកាតារាង“ក”ចំណូលថវិកាទូទៅរបស់រដ្ឋ និង តារាង “ខ” ចំណាយថវិកាទូទៅរបស់រដ្ឋ ។

-កិច្ចប្រតិបត្តិការនៃរតនាគារជាតិ ។

-ទំនាក់ទំនងហិរញ្ញវត្ថុរបស់រដ្ឋ ជាមួយនឹងធនាគារជាតិនៃកម្ពុជា ។

តុល្យភាពហិរញ្ញវត្ថុដែលសំរេចបានជាស្ថាពរ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ បានឆ្លុះបញ្ចាំងនៅក្នុងតារាងនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋដូចខាងក្រោម :

www.pheakdeylaw.com

ឯកតា: លានរៀល

| តារាងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ | ចំនួនទឹកប្រាក់ | ចំនួនលើស(+)/ ឱនភាព(-) |
|---|---|---|
| I- ចំណូលក្នុងប្រទេស | ១.៧៦៤.៦០៧ | |
| I- ១ ចំណូលចរន្ត | ១.៧៣៣.២៣២ | |
| I- ២ ចំណូលជាមូលធនក្នុងប្រទេស (ឯកជនភាវូបនីយកម្ម) | ៣១.៣៧៥ | |
| II- ចំណាយថវិកា | ២.៩២៨.៨២៥ | |
| II-១ ចំណាយចរន្ត | ១.៧៥៨.១៤៤ | |
| II-២ ចំណាយជាមូលធន[2] | ១.១៧០.៦៨២ | |
| ក្នុងនោះ ÷ | | |
| + វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ៣៣៣.១៩០ | |
| -ដោយមូលនិធិថវិកា | ២៦៦.៩៣៣ | |
| • គំរោងវិនិយោគ (សាងសង់,ទិញសម្ភារៈ) | ១៩៨.១៣៧ | |
| • បដិភាគរួមចំណែកជាមួយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៦៨.៧៩៦ | |
| -ដោយមូលនិធិក្រៅប្រទេសដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ | ៦៦.២៥៧ | |
| + វិនិយោគសាធារណៈដោយហិរញ្ញប្បទានពីក្រៅប្រទេសផ្ទាល់(ជំនួយគំរោងការ) | ៨៣៧.៤៩២ | |
| ក. ឱនភាពថវិកាចរន្ត (តាមនិយមន័យសន្យាផ្តល់) ( I.១ - II.១. ) | | (-) ២៤.៩១២ |
| ខ. ឱនភាពនៃថវិកាទូទៅ (តាមនិយមន័យសន្យាផ្តល់ )( I. – II. ) | | (-)១.១៦៤.២១៨ |
| III កំណែតម្រូវ | | (+)១៧២.២០៥[3] |
| អតិរេកនៃថវិកាចរន្ត (តាមនិយមន័យបេឡា) = ( III. + ក. ) | | (+)១៤៧.២៩៣ |
| ឱនភាពនៃថវិកាទូទៅ (តាមនិយមន័យបេឡា) = ( III. + ខ. ) | | (-) ៩៩២.០១៣ |
| IV- ហិរញ្ញប្បទាននៃឱនភាព | | (+)៩៩២.០១៣ |
| ១-ហិរញ្ញប្បទានក្រៅប្រទេស | | (+) ៨៨៦.០៩១ |
| • ជំនួយទ្រទ្រង់ថវិកាដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ | | (+)១៣៩.០៣១ |
| • ជំនួយគំរោងការ | | (+)៨០៦.៣៤០[4] |
| • ការរំលស់បំណុលបរទេស | | (-) ៥៩.២៨០ |
| ២-ហិរញ្ញប្បទានក្នុងប្រទេស | | (+)១០០.៤៤៨ |
| • ហិរញ្ញប្បទានធនាគារ | | (-)៥.៣០២ |
| ក្នុងនោះ - ខ្ចីពីធនាគារ | | — |
| - ការរំលស់បំណុលក្នុងប្រទេស | | (-)១.៨៨៣ |
| • ប្រាក់បញ្ញើផ្សេងៗទៀតនៃរតនាគារ | | (+)៥១.៩៧៥ |
| • វិស័យឯកជន | | (+) ៥១.៧៦៣ |
| • លំអៀងគណនីរវាងធនាគារជាតិនិងហិរញ្ញវត្ថុ | | (+)២.០១២ |
| ៣- កិច្ចប្រតិបត្តិការកំពុងដំណើរការ | | (+)៥.៤៧៤ |

[2] មិនបានគិតការរំលស់បំណុល ១១៥.៩១៧ លានរៀល ។ [3] បម្រែបម្រួលសុទ្ធនៃអាណត្តិបើកប្រាក់ ដែលមានសល់មិនទាន់បានបើកផ្តល់ទៅធនាគារ និងបរិប្បទានត្រូវធ្វើនិយ័តភាវូបនីយកម្ម ។ [4] ទៅមិនទាន់គិតចូលចំនួន ៣១.១៥២ លានរៀល ដែលបានចំណាយហើយ ។

www.pheakdeylaw.com

# ជំពូកទី ៥

## បទប្បញ្ញត្តិស្តីពីការទូទាត់ថវិកា

## របស់ខេត្ត ក្រុងសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

**មាត្រា ៨.-**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ១៨ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យ-សម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម.០២៩៨.០៣, ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ និង មាត្រា ១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ត្រូវបានយល់ព្រមតាមការអនុវត្តន៍នូវកិច្ចប្រតិបត្តិការចំណូល និង ចំណាយថវិការបស់ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ដែលលេចចេញជាលទ្ធផលដូចបានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ :

ឯកតា: រៀល

| កិច្ចប្រតិបត្តិការចំណូល និង ចំណាយថវិការបស់ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៣ | ការអនុវត្តន៍ថវិកាខេត្ត ក្រុងឆ្នាំ ២០០៣ | លើស(+) ខ្វះ (-) |
|---|---|---|---|
| សរុបចំណូល | ៨៩.០០០.០០០.០០០ | ៨៥.៧៧០.៨៧៧.១២៥ | -៣.២២៩.១២២.៨៧៥ |
| សរុបចំណាយ | ៨៩.០០០.០០០.០០០ | ៨៥.៣៩២.៩៥៦.១០៩ | -៣.៦០៧.០៤៣.៨៩១ |
| អតិរេកគណនេយ្យនៃចំណូល និង ចំណាយ | | ៣៧៧.៩២១.០១៦ | +៣៧៧.៩២១.០១៦ |
| កិច្ចប្រតិបត្តិការនៃថវិការបស់ខេត្ត ក្រុង | | | |
| I. ចំណូលថវិកា | ៨៩.០០០.០០០.០០០ | ៨៥.៧៧០.៨៧៧.១២៥ | -៣.២២៩.១២២.៨៧៥ |
| -ចំណូលចរន្ត | ៨៩.០០០.០០០.០០០ | ៨៥.៧៧០.៨៧៧.១២៥ | -៣.២២៩.១២២.៨៧៥ |
| • ចំណូលសារពើពន្ធ | ៤១.៧០០.០០០.០០០ | ៣៨.៨២២.១៦០.៧១៨ | -២.៨៧៧.៨៣៩.២៨២ |
| • ចំណូលពុំមែនសារពើពន្ធ | ១០.៣០០.០០០.០០០ | ៩.៩៤៨.៧១៦.៤០៧ | -៣៥១.២៨៣.៥៩៣ |
| • ឧបត្ថម្ភពីថវិការដ្ឋ | ៣៧.០០០.០០០.០០០ | ៣៧.០០០.០០០.០០ | ០ |
| -ចំណូលជាមូលធន | ០ | ០ | |
| • ចំណូលជាមូលធនផ្ទៃក្នុង | ០ | ០ | |
| • ចំណូលជាមូលធនទៅវិនិយោគដោយថវិការដ្ឋ (កម្មវិធីសិលា) | ០ | ០ | ០ |
| II. ចំណាយថវិកា | ៨៩.០០០.០០០.០០០ | ៨៥.៣៩២.៩៥៦.១០៩ | -៣.៦០៧.០៤៣.៨៩១ |
| -ចំណាយចរន្ត | ៨៩.០០០.០០០.០០០ | ៨៥.៣៩២.៩៥៦.១០៩ | -៣.៦០៧.០៤៣.៨៩១ |
| -ចំណាយជាមូលធន | ០ | ០ | ០ |
| III. អតិរេកថវិកា | ០ | ៣៧៧.៩២១.០១៦ | +៣៧៧.៩២១.០១៦ |

**មាត្រា ៩.–**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ២២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យ-សម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស.រកម.០២៩៨.០៣, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ អតិរេកនៃថវិការបស់ខេត្ត ក្រុង ដែលមានចំនួនទឹកប្រាក់ ៣៧៧.៩២១.០១៦ រៀល ត្រូវបានបង់ចូលថវិកាទូទៅរបស់រដ្ឋ ។

## ជំពូកទី ៦
## បទប្បញ្ញត្តិស្តីពី
## និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការ
## ចំណាយថវិកាបន្ថែមសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣

**មាត្រា ១០.–**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ៤៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និង បទប្បញ្ញត្តិនានានៃវិសោធនកម្មច្បាប់នេះ និងមាត្រា ៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៤/០០៥ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ ត្រូវបានអនុម័តយល់ព្រមឱ្យចំណាយថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ដូចខាងក្រោម :

- ចំណាយសំរាប់រៀបចំកិច្ចប្រជុំអភិបាលក្រុងប្រើភាសាបារាំងចំនួន ២.២០០ លានរៀល
- ចំណាយក្នុងក្របខ័ណ្ឌនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៣ ចំនួន ១៣.១៦៥ លានរៀល ។
- ចំណាយសំរាប់កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានឆ្នាំ ២០០៣ ចំនួន ៧.៨៨៥ លានរៀល

www.pheakdeylaw.com

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១២.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០០៦

នស/រកម.០១០៦.០១៩ **ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**គាត ឈន់**

លេខៈ ៣៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង គាន់

www.pheakdeylaw.com